ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ ០១៤ សជណ.សក.បជ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពីការលើកថ្ងៃប្រឡង ជ្រើសរើសបេក្ខជន ចូលបំរើការងារក្នុងក្របខណ្ឌក្រសួងសាធារណការ និងដឹកជញ្ជូន ឆ្នាំ២០១៦

យោងសេចក្តីជូនដំណឹងលេខ ០០៥ សជណ.សក.បជ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការលើកពេលប្រឡងជ្រើសរើសបេក្ខជនចូលបំរើការងារក្នុងក្របខណ្ឌក្រសួងសាធារណការ និងដឹកជញ្ជូន ឆ្នាំ២០១៦។

ក្រសួងសាធារណការ និងដឹកជញ្ជូន សូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងពីរភេទដែលបានដាក់ពាក្យប្រឡងចូលបំរើការងារក្នុងក្របខណ្ឌក្រសួងសាធារណការ និងដឹកជញ្ជូនឆ្នាំ២០១៦ ឲ្យបានជ្រាបថា ក្រសួងសូម **លើកកាលបរិច្ឆេទនៃការប្រឡង** ដែលបានកំណត់ធ្វើ**នៅថ្ងៃអាទិត្យទី ២៦ ខែ មិថុនា ឆ្នាំ២០១៦** លើកទៅធ្វើ **នៅថ្ងៃអាទិត្យទី ០៣ ខែ កក្កដា ឆ្នាំ២០១៦** នៅ **វិទ្យាល័យព្រះស៊ីសុវត្ថិ** និង **សាលាបឋមសិក្សាភ្នំដូនពេញ** ។

• ចំពោះព័ត៌មានផ្សេងៗ បេក្ខជនអាចសាកសួរនៅនាយកដ្ឋានបុគ្គលិក-ធនធានមនុស្ស នៃក្រសួងសាធារណការនិងដឹកជញ្ជូន រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈទូរស័ព្ទលេខ ០១២ ៥៣១ ៥៤៧ ០១២ ៨៩៣ ០៥៧ និង នៅតាមមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្តទាំង២៥។

អាស្រ័យហេតុនេះ សូមបេក្ខជនទាំងពីរភេទ ជ្រាបជាព័ត៌មាន។

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋាន និងមន្ទីរស.ក.ជ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ - កាលប្បវត្តិ